គ.ជ.អ.ប
NCDD

វគ្គបណ្ដុះបណ្ដាលគ្រូបង្គោលស្ដីពី
ការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម

# មេរៀនទី ១
# សេចក្ដីណែនាំអំពីការប្រមូល និងបញ្ចូលទិន្នន័យ

“Introduction to Data Collection and Data Entry”

បង្ហាញដោយ៖ អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន
នៃលេខាធិការដ្ឋានគ.ជ.អ.ប

រាជធានីភ្នំពេញ ថ្ងៃទី ២១ខែកុម្ភៈ ឆ្នាំ២០១៧

# មាតិកា

1. គោលបំណង
2. វដ្តនៃសកម្មភាពគណនេយ្យភាពសង្គម
3. លំហូរនៃដំណើរការប្រមូល និងដំណើរការបញ្ចូលទិន្នន័យ ការបោះពុម្ភ និងបិទផ្សាយ
4. ទម្រង់ប្រមូលទិន្នន័យទាំងបីវិស័យ
5. សូចនាករ
6. I4Cs
7. Post-On
8. JAAP

# គោលបំណង

ពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ខេត្ត អោយយល់ច្បាស់ពីវដ្តនៃគណនេយ្យភាពសង្គម និងលំហូរនៃដំណើរការប្រមូលទិន្នន័យទាំងបីវិស័យ(រដ្ឋបាលឃុំ សាលាបឋម និងមណ្ឌលសុខភាព) រហូតដល់ការបញ្ចូលទិន្នន័យទាំងបីវិស័យទៅក្នុងប្រព័ន្ធត្រួតពិនិត្យ តាមដានការអនុវត្តសកម្មភាពនេយ្យភាពសង្គម ដើម្បីបោះពុម្ពទិន្នន័យលទ្ធផលការងារ(Post-On)ដែលមានគុណភាពដល់អ្នកពាក់ព័ន្ធសម្រាប់ប្រើប្រាស់។

សំខាន់ជាងនេះទៅទៀតត្រូវយកចំណេះដឹងដែលទទួលបានពី វគ្គបណ្តុះបណ្តាលនេះទៅធ្វើការ បណ្តុះបណ្តាលបន្តទៅកាន់ស្រុកគោលដៅដោយភាពច្បាស់លាស់និង ត្រឹមត្រូវទៅតាមគោលការណ៍នៃការងារគណនេយ្យភាពសង្គមចង់បាន។

# វដ្តនៃគណនេយ្យភាពសង្គម



# ការប្រមូល បញ្ចូលទិន្នន័យទាំង ៣ តំណាក់កាល

មករា - មេសា

- ការប្រមូលទិន្នន័យ ការបញ្ចូល និងការផលិតPost-On

មេសា - កញ្ញា

- ការរាយការណ៍ និងការតាមដាន ការបិទផ្សាយI4Cs និង Post-On

កញ្ញា - តុលា

- ការបញ្ចូលព័ត៌មាន JAAP និងការផលិត Post-On របស់ JAAP

# អ្នកពាក់ព័ន្ធក្នុងការប្រមូលទិន្នន័យ

- មន្ត្រីបង្គោលគណនេយ្យភាពសង្គមនៅថ្នាក់ស្រុក គាំទ្រដោយទីប្រឹក្សាស្រុក និងDSO
- ប្រធានការិយាល័យផែនការគាំទ្រឃុំ សង្កាត់ និងមន្ត្រីការិយាល័យ
- ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងមន្ត្រីការិយាល័យ
- ប្រធានការិយាល័យអប់រំយុវជន និងកីឡាស្រុក និងមន្ត្រីការិយាល័យ
- ស្មៀនឃុំ និងក្រុមប្រឹក្សា
- ប្រធានមណ្ឌលសុខភាព និងបុគ្គលិកមណ្ឌលសុខភាព
- នាយកសាលាបឋមសិក្សា និងគ្រូបង្រៀន

# ការប្រមូលទិន្នន័យ
# ការបញ្ចូល និងការផលិតPost-On

# លំហូរនៃការផលិត Post-On



# តារាងសង្ខេបជំហានទាំង ៦ នៃការប្រមូលទិន្នន័យ និងការផលិតPost-On

| ល.រ | ជំហាន | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| ១ | បោះពុម្ព និងបែងចែកទម្រង់ប្រមូលទិន្នន័យដល់អ្នកពាក់ព័ន្ធ | មករា | មន្ត្រីISAFស្រុក* |
| ២ | បំពេញទម្រង់ប្រមូលទិន្នន័យ និងបញ្ជូនទិន្នន័យត្រលប់វិញ | កុម្ភៈ | ឃុំ មណ្ឌលសុខភាព សាលារៀន |
| ៣ | ការផ្ទៀងផ្ទាត់ទិន្នន័យប្រមូលបាន និងកែតម្រូវ | មិនា | មន្ត្រីISAFស្រុក* |
| ៤ | បញ្ចូលទិន្នន័យ និងបោះពុម្ពPost-On | មិនា | មន្ត្រីISAFស្រុក* |
| ៥ | រៀបចំផ្សព្វផ្សាយ I4Cs ដល់អ្នកពាក់ព័ន្ធ | មេសា | ការិយាល័យគាំទ្រឃុំ សង្កាត់ |
| ៦ | បិទផ្សាយ I4Cs និងPost-On | មេសា | ឃុំ សហការជាមួយCAF |

* *មន្ត្រីបង្គោលគណនេយ្យភាពសង្គមនៅថ្នាក់ស្រុក*

# ទម្រង់ប្រមូលទិន្នន័យទាំង៣ វិស័យ



## លេខសូន្យ (0) vs. ចន្លោះទទេរ (ចំហរ)

# របៀបបោះពុម្ពទម្រង់

- ចូលទៅកាន់អាសយដ្ឋានគេហទំព័រ៖

*mis.ncdd.gov.kh/isaf*



# អំពីសូចនាករទាំង៣ វិស័យ



# និងរបៀបបំពេញទម្រង់ប្រមូលទិន្នន័យ

# កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ

ផ្ទាំងព័ត៌មានសរុបមាន ៩ ផ្ទាំងផ្សេងគ្នា ៖

- **ផ្ទាំងព័ត៌មានសម្រាប់រដ្ឋបាលឃុំ ៣ផ្ទាំង**
  - សិទ្ធិរបស់អ្នកនៅឃុំ
  - ការបំពេញតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ
  - ថវិការបស់ឃុំ
- **ផ្ទាំងព័ត៌មានសម្រាប់មណ្ឌលសុខភាព ៣ផ្ទាំង**
  - សិទ្ធិរបស់អ្នកនៅមណ្ឌលសុខភាព
  - ស្តង់ដាមណ្ឌលសុខភាព
  - ថវិការ និងការងាររបស់មណ្ឌលសុខភាព
- **ផ្ទាំងព័ត៌មានសម្រាប់សាលាបឋមសិក្សា ២ផ្ទាំង**
  - សិទ្ធិរបស់អ្នកនៅសាលារៀន
  - ថវិការ និងការបំពេញការងាររបស់សាលាបឋមសិក្សា
- **ផ្ទាំងព័ត៌មានចុងក្រោយសម្រាប់បិទផ្សាយផែនការសកម្មភាពសង្គមរួមស្តីពីគណនេយ្យភាពសង្គម ដែលបានឯកភាពគ្នា ១ផ្ទាំង**




# សិទ្ធិប្រជាពលរដ្ឋ

- ក្រុមប្រឹក្សាបោះឆ្នោត ដោយ ប្រជាពលរដ្ឋ ហេតុនេះ ត្រូវតែជា តំណាង និងត្រូវមានគណនេយ្យភាពជាមួយប្រជាពលរដ្ឋ។
- ត្រូវស្តាប់យោបល់ប្រជាពលរដ្ឋ។
- ត្រូវអញ្ជើញប្រជាជាពលរដ្ឋប្រជុំ
- ប្រជាពលរដ្ឋ អាចសួរ ក្រុមប្រឹក្សា អំពីសេវា និងគម្រោងនានាបាន
- ការផ្តល់សេវាជូនប្រជាពលរដ្ឋ
- ការផ្សព្វផ្សាយព័ត៌មាន

ជួយកែលម្អឃុំសង្កាត់អ្នក ...!?




# ការអនុវត្តការងារ

- ស្រុកត្រូវ ព្រីនទិន្នន័យ បិទនៅតាមប្រទេ្បាះ ចំហ ទី១ និងទី២ ដែលបង្ហាញអំពីការបំពេញការងារ របស់ឃុំនីមួយៗ

1. បានប្រជុំក្រុមប្រឹក្សាឬទេ ?
2. ថាតើ ឃុំមានបានពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែរឬទេ ?
3. បានចេញលិខិតអត្រានុកូលដ្ឋាន ក្នុងរង្វង់៣ថ្ងៃដែរឬទេ ?
4. បានតាមដានការអនុវត្តគម្រោង តាមរយៈគណៈកម្មការគ្រប់គ្រងគម្រោងដែរឬទេ ?
5. បានផ្សព្វផ្សាយព័ត៌មានជាសាធារណៈដែរឬទេ ?
6. បានរៀបចំ ផ.ស.គ.រ ដែរឬទេ ?




# ថវិកាឃុំ

- ស្រុកត្រូវព្រីនព័ត៌មាន និង បិតនៅប្រឡោះទាំង៣ ដែលរួមមាន៖

1. ចំណូលរបស់ឃុំ
2. ចំណាយរបស់ឃុំ
3. ការប្រើប្រាស់ថវិកាឃុំ តាមរយៈគម្រោងផ្សេងៗ




# សិទ្ធិប្រជាពលរដ្ឋ សម្រាប់ការអប់រំ

- ចូលរៀនដោយឥតគិតថ្លៃ រហូតដល់ចប់ថ្នាក់ទី៩
- គ្រូម្នាក់ សម្រាប់សិស្ស៤២នាក់ ក្នុង១ថ្នាក់
- បង្រៀនឱ្យបាន២២៨ថ្ងៃ /ឆ្នាំ
- សៀវភៅ៣-៤ក្បាល ក្នុងម្នាក់
- មានបង្គន់អនាម័យ សម្រាប់សិស្ស ស្រី និងសិស្សប្រុស
- ជួយសិស្សរៀនសូត្រ ដោយស្មើៗគ្នា ស្រឡាញ់ស្មើៗគ្នា មិនទាមទារបង់ប្រាក់ក្រៅ ...។ល។




# ការអនុវត្តការងារ និងថវិកា

- ស្រុកត្រូវជួយ សាលារៀន ក្នុងការបិតផ្សាយ៖

1. ចំណូលរបស់សាលារៀន
2. ចំណាយរបស់សាលារៀន
3. ការបំពេញការងារ
    1. អាត្រាក្មេងចូលរៀន
    2. មានគ្រូបំពេញគ្រប់គ្រាន់
    3. បង្រៀនបាន២២៨ថ្ងៃ/ឆ្នាំ
4. ការបំពេញការងារ
    1. ផ្តល់សៀវភៅ៣-៤ក្បាល
    2. អត្រាប្រឡងជាប់ខ្ពស់
    3. អត្រាសិស្សរៀនចប់ថ្នាក់ទី៦




# សិទ្ធិប្រជាពលរដ្ឋ

- ផ្តល់សេវាដោយស្មើៗភាពគ្នា
- បង្ហាញជូនពីសេវាសុខភាព
- ជួយពន្យល់អំពីបញ្ហាសុខភាព
- បង់ប្រាក់តាមតារាងតម្លៃ
- រក្សាការសម្ងាត់របស់អ្នកជម្ងឺជាពិសេសស្ត្រី
- មានការយល់ព្រម និងទទួលយោបល់ត្រឡប់




# ស្តង់ដារការងារ

- មានបុគ្គលិក ពី៨-១២ នាក់
- ត្រូវមានវេន ប្រចាំការ២៤ ម៉ោង
- ត្រូវទទួលថ្នាំ១២ដង/ឆ្នាំ
- មានបង្គន់ ដាច់ដោយឡែក
- ប្រជុំគណៈកម្មការ១២ដង/ឆ្នាំ
- ត្រូវបិទផ្សាយព័ត៌មាន សាធារណៈ




# ផែនការសកម្មភាព គណនេយ្យភាពរួម

- បន្ទាប់ពីបានព្រមព្រៀងក្នុងកិច្ចប្រជុំរួម ស្រុកត្រូវជួយ រៀបចំ និងបិទផ្សាយ ផែនការសកម្មភាពគណនេយ្យភាពរួម នៅលើផ្ទាំងព័ត៌មាននេះ។ សកម្មភាពទាំងនោះ អាចអនុវត្ត ដោយ៖

1. រួមគ្នា
2. សហគមន៍
3. អ្នកផ្តល់សេវា
4. ក្រុមប្រឹក្សាឃុំ
5. ថ្នាក់ស្រុក

រូបភាពនានា អាចបិទបាននៅប្រឡោះចំហធំខាងក្រោម។

# គំរូតារាង JAAP






# Post-On

- Post-On គឺជាលទ្ធផលបានមកពី ការបញ្ចូលទិន្នន័យ ទាំង ៣ វិស័យ

# ការរាយការណ៍ និងការតាមដាន

# ការបើកផ្សាយ 4Cs និង Post-Ons

# *តារាងសង្ខេបជំហានទាំង ៦ នៃការរាយការណ៍ និងការតាមដាន ការបិទផ្សាយI4Cs និងPost-Ons*

| ល.រ | ជំហាន | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| ១ | ការបោះពុម្ព បែងចែក *ទម្រង់ស្វ័យរាយការណ៍* ការបិទផ្សាយI4Cs និង Post-On ដល់អ្នកពាក់ព័ន្ធ | មេសា | មន្ត្រីISAFស្រុក* |
| ២ | បំពេញ *ទម្រង់ស្វ័យរាយការណ៍* និងបញ្ជូនទិន្នន័យត្រលប់វិញ | ឧសភា ដល់ មិថុនា | ឃុំ មណ្ឌលសុខភាព សាលារៀន |
| ៣ | ការផ្ទៀងផ្ទាត់ទិន្នន័យប្រមូលបាន និងបញ្ចូលទិន្នន័យ *ទម្រង់ស្វ័យរាយការណ៍* | កក្កដា | មន្ត្រីISAFស្រុក* |
| ៤ | ការបោះពុម្ព បែងចែក *ទម្រង់តាមដាន* ការបិទផ្សាយI4Cs និងPost-On ដល់អ្នកទទួលខុសត្រូវក្នុងការតាមដានការបិទផ្សាយ (CAF) | កក្កដា | មន្ត្រីISAFស្រុក* |
| ៥ | បំពេញ *ទម្រង់តាមដាន* និងបញ្ជូនទិន្នន័យត្រលប់វិញ | សីហា | CAF |
| ៦ | ការផ្ទៀងផ្ទាត់ទិន្នន័យប្រមូលបាន និងបញ្ចូលទិន្នន័យ *ទម្រង់តាមដាន* | កញ្ញា | មន្ត្រីISAFស្រុក* |

* *មន្ត្រីបង្គោលគណនេយ្យភាពសង្គមនៅថ្នាក់ស្រុក*

# ទម្រង់ស្ន័យរាយការណ៍ និងទម្រង់តាមដាន ការបិទផ្សាយI4Cs និងPost-On



# ការបញ្ចូលព័ត៌មាន JAAP
# និងការផលិត Post-On របស់ JAAP

# តារាងសង្ខេបជំហានទាំង ៤ នៃការបញ្ចូលព័ត៌មាន JAAP និងការផលិត Post-On JAAP

| ល.រ | ជំហាន | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| ១ | ទទួលតារាង ពីដៃគូរពាក់ព័ន្ធ (អង្គការសង្គមស៊ីវិល និងមន្ត្រីបង្គោលថ្នាក់ឃុំ) | កញ្ញា | មន្ត្រីISAFស្រុក* |
| ២ | បញ្ចូលទិន្នន័យ JAAP | កញ្ញា | មន្ត្រីISAFស្រុក* |
| ៣ | បោះពុម្ព Post-On របស់ JAAP និងបែងចែកដល់អ្នកពាក់ព័ន្ធ | តុលា | មន្ត្រីISAFស្រុក* |
| ៤ | បិតផ្សាយ Post-On របស់ JAAP | តុលា | ឃុំ មណ្ឌលសុខភាព សាលារៀន |

* មន្ត្រីបង្គោលគណនេយ្យភាពសង្គមនៅថ្នាក់ស្រុក

# សូមអរគុណ